# ព្រះវិហារ១០០ឆ្នាំ ក្នុងវត្តព្រះប្រសប់និងចម្លាក់រឿងព្រះជិនវង្ស

វត្តព្រះប្រសប់ កសាងឡើងនៅប្របដងទន្លេមេគង្គត្រើយខាងកើត ស្ថិតក្នុងឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ ទីធ្លាវត្តនេះធំទូលាយ ដោយមានផ្នែកខាងលិចជាប់ទន្លេ ហើយផ្នែកខាងកើតទល់នឹងផ្លូវជាតិ។ បច្ចុប្បន្នគេឃើញវត្តនេះជាអារាមព្រះពុទ្ធសាសនា មានសំណង់ប្រពៃណីជាច្រើនដែលបានសាងឡើងក្នុងកាលសម័យផ្សេងៗគ្នាមកជាបន្តបន្ទាប់។ ក្នុងបណ្តាសំណង់ទាំងនោះ គឺមានព្រះវិហារមួយសាងឡើងស្ទើរចំកណ្តាលទីធ្លាវត្ត មានសភាពល្អប្លែកទាំងទម្រង់ស្ថាបត្យកម្ម សិល្បៈតុបតែងលម្អ ព្រមទាំងមានគំនូរចម្លាក់ផ្សេងៗ ដែលគួរតែសិក្សាស្វែងយល់ ជាពិសេសគឺចម្លាក់រឿងព្រះជិនវង្សនៅជញ្ជាំងបាំងសាចជុំវិញព្រះវិហារ។ ផ្នែកខាងមុខព្រះវិហារទៀតសោតគេសាងព្រះចេតិយធំពីរទន្ទឹមគ្នាសឹងតែប្រកបដោយក្បាច់រចនាតាមក្បួនខ្នាតជាព្រះចេតិយលាតបែបបុរាណ (រូបលេខ១)។



រូបលេខ១ ព្រះវិហារវត្តព្រះប្រសប់ មើលពីទិសខាងកើត

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ព្រះវិហារវត្តព្រះប្រសប់ ជាស្ថាបត្យកម្មពុទ្ធសាសនាតាមដងទន្លេ ដែលសាងឡើងពីបេតុង ហើយបានជួសជុលថែទាំរហូតគង់វង្សដល់សព្វថ្ងៃ។ បើតាមចំណារសារបានវត្តកត់ចំណាំថា "ឆ្នាំខាល អដ្ឋស័កបានសាងព្រះវិហារ ពុទ្ធសករាជបាន២៤៦៩"។ តាមពុទ្ធសករាជខាងលើនេះ ក៏ត្រូវនឹងការសិក្សារបស់អ្នកស្រាវជ្រាវ Danielle & Dominique-Pierre Guéret យល់ថាព្រះវិហារវត្តព្រះប្រសប់សាងឡើងក្នុងឆ្នាំ១៩២៦។[1] ដូច្នេះបើគិតរាប់តាំងពីសាងព្រះវិហារ (ឆ្នាំ១៩២៦) មកដល់បច្ចុប្បន្ន (ឆ្នាំ២០២៦) ព្រះវិហារវត្តព្រះប្រសប់មានអាយុកាល១០០ឆ្នាំគត់។

បន្ថែមពីលើនេះ បើមើលតាមរូបថតឆ្នាំ១៩២៩ គេឃើញសំណង់ខ្លោងទ្វារមួយយ៉ាងល្អវិចិត្រសាងជាប់ច្រាំងទន្លេ ដែលទំនងស្ថិតនៅខាងលិចព្រះវិហារ (រូបលេខ២២)។ បច្ចុប្បន្នខ្លោងទ្វារនោះពុំមានទៀតឡើយ តែបើធៀបទៅនឹងខ្លោងទ្វារទាំងបួននៃខឿនជុំវិញព្រះវិហារដែលមានដល់សព្វថ្ងៃ ក៏ឃើញមានទម្រង់សិល្បៈប្រហាក់ប្រហែលខ្លោងទ្វារចាស់នោះដោយអន្ទើដែរ (រូបលេខ២៣)។ ប៉ុន្តែយ៉ាងណាក្ដី តាមចំណារសារបានវត្តកត់បញ្ជាក់ថា ខឿនព្រះវិហារសាងឡើងក្នុងពុទ្ធសករាជ២៤៧៩ (ឆ្នាំ១៩៣៧)។ ដូច្នេះគេអាចយល់បានថា ខ្លោងទ្វារទាំងបួនទិសជុំវិញព្រះវិហារនោះ សាងក្រោយព្រះវិហារ១០ឆ្នាំ តែប្រហែលយកលំនាំសិល្បៈតាមអតីតខ្លោងទ្វារចាស់ជាប់មាត់ទន្លេ។



*រូបលេខ២២ ខ្លោងទ្វារចាស់ (រូបថត៖ EFEO, 1929)*



*រូបលេខ២៣ ព្រះវិហារ និងខ្លោងទ្វារខឿនទិសខាងលិច*

---

[1] ដានីញ៉ែល និង ដូមីនិក-ព្យែរ ហ្គេរេត៍, ២០២៥, ១៧២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដោយឡែក ចំពោះលក្ខណៈស្ថាបត្យកម្មព្រះវិហារវត្តព្រះប្រសប់ដែលមើលឃើញសព្វថ្ងៃនេះ ធ្លាប់បានជួសជុលមកជារឿយៗដូចបានបញ្ជាក់ខាងលើ។ ព្រះវិហារប្រភេទនេះគេចាត់ជាព្រះវិហារជហ្វាបួន ដែលមានដំបូលកិងប្រក់ក្បឿងស្រកាលេញជ្រាលចុះសងខាងពីរថ្នាក់ មានជហ្វានៅចុងព្រំដំបូលខាងមុខចំនួនពីរ និងចុងព្រំដំបូលខាងក្រោយចំនួនពីរៗ[2] តាមចុងបែងនីមួយៗលម្អដោយនាគបែង ដែលជាប្រភេទចម្លាក់ពុម្ពស៊ីម៉ង់ត៍។ ហោជាងទាំងពីរនៃព្រះវិហារនេះ រចនាលម្អដោយក្បាច់ភ្ញីយ៉ាងសាមញ្ញលាបពណ៌លឿងរំលេចលើផ្ទៃហោជាងពណ៌ដីលែង (ឬពណ៌ជ្រូក?)។ ប៉ុន្តែលើហោជាងខាងកើតមានដាំកញ្ចក់តាមសន្ទឹកក្បាច់ខ្លះ ហើយត្រង់ផ្នែកកណ្ដាលទំនងជារូបឆ័ត្ររួតមួយគូ អមដោយរាជសីហ៍គជសីហ៍(?) ដែលមានចម្លាក់ទេពមួយអង្គហោះនៅខាងលើ (រូបលេខ២៤)។ ចំណែកឯនៅត្រង់ផ្នែកកណ្ដាលនៃហោជាងខាងលិច មានចម្លាក់សត្វនាគមួយគូទ្រជើងពានដែលតម្កល់គម្ពីរនៅខាងលើ និងអមដោយឆ័ត្ររួតមួយគូ ហើយមានចម្លាក់តូចៗជារូបមនុស្សបួននាក់អង្គុយប្រណមសងខាង។ នៅលើហោជាងខាងលិចនេះដែរ មានចំណារបញ្ជាក់ការជួសជុលនៅក្នុងដើមឆ្នាំ២០០៦ (រូបលេខ២៥)។ ដូច្នេះបើផ្អែកតាមចំណារនេះទំនងជារចនាសម្ព័ន្ធគ្រឿងបង្គុំដំបូលព្រះវិហារទាំងមូល បានជួសជុលជាថ្មីក្នុងពេលទន្ទឹមគ្នានឹងការជួសជុលហោជាងទាំងពីរដែរ ដ្បិតឃើញមានការប្រើពណ៌ថ្មីភ្លឺផ្ទេកដូចគ្នាទាំងអស់នូវគ្រប់ផ្នែកនៃរចនាសម្ព័ន្ធខាងលើ។



រូបលេខ២៤ ហោជាងខាងកើត



រូបលេខ២៥ ហោជាងខាងលិច

---

[2] ព្រាប ចាន់ម៉ារ៉ា, ២០១៧: ១៣-២៣

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត

ចំណែកឯរចនាសម្ព័ន្ធ និងការតុបតែងលម្អនៅផ្នែកខាងក្រោមគ្រឿងបង្គុំដំបូល គេឃើញនៅលើជញ្ជាំងជុំវិញនៃផ្នែកខាងក្រៅមានចម្លាក់ផាកប្រយុទ្ធរវាងយក្ស និងស្វាលើស៊ុមក្បាច់នៃទ្វារ និងបង្អួចនីមួយៗ។ នៅគល់សសរជាប់ជញ្ជាំងវិញ លម្អដោយចម្លាក់រូបរាជសីហ៍គជសីហ៍ (រូបលេខ៦-៧)។ ប៉ុន្តែនៅផ្នែកខាងលើនៃក្បាលសសរជុំវិញបាំងសាចជាសិល្បៈចម្លាក់ផុះមួយបែបមានសាច់រឿងព័ទ្ធជុំវិញទាំងបួនទិស។ អ្នកស្រាវជ្រាវអំពីវត្តអារាមខ្មែរយល់ថា ចម្លាក់នេះជារឿងទសជាតក។[3] ផ្ទុយទៅវិញ បើផ្អែកតាមការសិក្សាផ្សេងទៀតយល់ថាសាច់រឿងចម្លាក់ទាំង៣០ផ្ទាំងនោះ ជារឿងព្រះជិនវង្សដែលមានប្រជាប្រិយបំផុតក្នុងសង្គមខ្មែរ នៅពាក់កណ្តាលសតវត្សរ៍ទី២០។ របៀបមើលចម្លាក់នេះពីដើមមកចុងគឺត្រូវផ្តើមពីមុមនិរតីនៃជញ្ជាំងខាងលិច ហើយដើរមើលជាប្រទក្សិណ មានន័យថាដើរសំដៅទៅមុមពាយ័ព្យ បន្ទាប់មកទៅមុមឦសាន មកទល់គ្នាវិញនឹងមុមនិរតីនៃជញ្ជាំងខាងត្បូងវិញ (រូបលេខ៨-១១)។[4]




រូបលេខ៦-៧ រចនាសម្ព័ន្ធ និងសិល្បៈលម្អផ្នែកលើជញ្ជាំងជុំវិញដែលមានសាច់រឿងព្រះជិនវង្ស

រឿងព្រះជិនវង្សបើសង្ខេបខ្លីមានសេចក្តីថាព្រះជិនវង្សជាបុត្រាព្រះបាទសុវណ្ណវង្ស និងព្រះនាងជិនបុប្ផា។ ដោយសារក្តីច្រណែនរបស់ព្រះស្នំពីរអង្គគឺ នួនធីតា និងរត្នវេខា បានរៀបឧបាយកលដាក់ថ្នាំបំពុលសម្លាប់ព្រះជិនវង្ស តែបែរជាធ្វើឱ្យបុត្រារបស់ស្នំទាំងពីរសោយអាហារនោះរហូតដល់សុគត។ ព្រះស្នំទាំងពីរបានទម្លាក់កំហុសលើព្រះជិនវង្ស

[3] Danielle & Dominique-Pierre Guéret; 2017, 105

[4] វណ្ណ វិរៈបុត្រ, ២០២០, ទំ. ៥១-៧៦

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ធ្វើឱ្យព្រះរាជាគ្រោធខឹងយ៉ាងខ្លាំង រហូតបញ្ជាឱ្យគេយកព្រះជិនវង្សដាក់ទ្រុងដែកបោះចូលក្នុងសមុទ្រ។ ដោយបុណ្យកុសល ព្រះជិនវង្សត្រូវស្តេចកុជង្គនាគជួយសង្គ្រោះជីវិត។ បន្ទាប់មកព្រះអង្គបានចេញផ្សងព្រេងយ៉ាងកម្សត់ រៀនសិល្បវិជ្ជា និងមានមហេសីចំនួន៤អង្គ។ ក្រោយពេលបានជួបជុំព្រះបិតាវិញ ព្រះអង្គបានគង់នៅយ៉ាងមានសុភមង្គល រហូតដល់ថ្ងៃដែលមហេសីទាំង៤ ត្រូវត្រឡប់ទៅនគររៀងៗខ្លួនវិញ ទើបព្រះជិនវង្សសម្រេចព្រះទ័យចេញទៅសាងផ្នួសជាឥសីនៅព្រៃហេមពាន្តរហូតដល់អស់ព្រះជន្ម។[5]



រូបលេខ៨-១១ អន្ទើខ្លះៗនៃចម្លាក់រឿងព្រះជិនវង្សនៅវត្តព្រះប្រសប់

ផ្នែកខាងក្នុងព្រះវិហារ គេសាងបល្ល័ង្កព្រះដីវ៍ធំនៅក្បែរជញ្ជាំងខាងលិច ដូចនៅបណ្តាព្រះវិហារដទៃដែរ។ ប៉ុន្តែបល្ល័ង្កនិងព្រះដីវ៍នេះសាងជាថ្មីក្រោយសម័យសង្គ្រាមក្នុងឆ្នាំ១៩៨៦ ដោយព្រះបដិមាសាងឡើងក្នុងកាយវិការយកព្រះធរណីជាសាក្សី (ភូមិស្បស់) មានព្រះហស្តស្តាំដាក់លើព្រះបាទចង្អុលចុះទៅផែនដី (រូបលេខ១២)។ ផ្នែកខាងក្រោយបល្ល័ង្កមានឆ្លាក់រូបនាងគង្ហីងច្បួតសក់ឈរលើក្រពើ។ ចំពោះគំនូរលើជញ្ជាំងជុំវិញមានបី

5 ពុទ្ធសាសនបណ្ឌិត្យ, ១៩៦២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ជួរ គឺសាច់រឿងពុទ្ធប្រវត្តិនៅជួរលើបំផុត និងរឿងក្នុងជាតកគូរជាពីរជួរខាងក្រោម ហើយគំនូរទាំងនេះគូរក្នុងឆ្នាំ១៩៦៧ (រូបលេខ១៣-១៥)។



រូបលេខ១២ បល្ល័ង្កនិងបដិមាព្រះជីវ៍



រូបលេខ១៣ គំនូរពុទ្ធប្រវត្តិ "ទ្រង់ចូលបរិនិព្វាន"



រូបលេខ១៤ គំនូរពុទ្ធប្រវត្តិ "ចែកព្រះសារីរិកធាតុ"



រូបលេខ១៥ គំនូររឿងជាតកនានា

ជារួមមកព្រះវិហារវត្តព្រះប្រសប់ គឺជាបេតិកភណ្ឌស្ថាបត្យកម្មពុទ្ធសាសនាដ៏មានតម្លៃតាមដងទន្លេ ដែលមានអាយុកាល១០០ឆ្នាំគត់គិតត្រឹមឆ្នាំ២០២៦។ ភាពពិសេសវិសាលបំផុតនៃព្រះវិហារនេះ គឺសិល្បៈចម្លាក់ផ្ទះទាំង៣០ ផ្ទាំងដែលបង្ហាញពីរឿង "ព្រះជិនវង្ស" នៅលើជញ្ជាំងបាំងសាចជុំវិញ។ ទោះបីជាឆ្លងកាត់ការជួសជុលជាបន្តបន្ទាប់ និងមានការផ្លាស់ប្តូរខ្លះៗលើសំណង់ខ្លោងទ្វារ និងបដិមាព្រះជីវ៍តាមសម័យកាលក៏ដោយ ក៏អាពមនេះនៅតែរក្សាបាននូវអត្តសញ្ញាណសិល្បៈខ្មែរយ៉ាងរឹងមាំ និងជាកន្លែងសិក្សាដ៏សំខាន់អំពីទំនាក់ទំនងរវាងអក្សរសិល្ប៍ និងសិល្បៈចម្លាក់ក្នុងសង្គមខ្មែរ។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ដានីញែល និង ដូមីនិក-ព្យែរ ហ្គេរេត៍

២០២៥, *វត្តអារាមនៅប្រទេសកម្ពុជា៖ ពណ៌ពីអតីតកាល ពិព័រណ៍មិនអចិន្ត្រៃយ៍,* ធនាគារជាតិនៃកម្ពុជា, ភ្នំពេញ

ព្រាប ចាន់ម៉ារ៉ា

២០១៧, *សំណង់នៅតាមវត្ត*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ

វណ្ណ វិរៈបុត្រ

២០២០, "ចម្លាក់រឿងព្រះជិនវង្សនៅវត្តព្រះប្រសប់", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ,* លេខ១៥, ទំ.៥១-៧៦, យសោធរ, ភ្នំពេញ

ពុទ្ធសាសនបណ្ឌិត្យ

១៩៦៤, *រឿងព្រះជិនវង្ស ខ្សែ១*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

Danielle & Dominique-Pierre Guéret

2017, *The Khmer Pagoda*, KAM Edition, Phnom Penh

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត